ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

**COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)**

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,

Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN Saray
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ និងជានាយក CCPCR

លោក **យ៉ៀង វណ្ណា**
Mr. YEANG Vanna
ប្រធាន KKKHRA

លោក **ជីវ យូម៉េង**
Mr. CHIV You Meng
ប្រធាន KYA

លោកស្រី **ពឹង យក់ហៀប**
Ms. PEUNG Yok Hiep
នាយិកា LAC

លោក **យង់ គិមអេង**
Mr. YONG Kim Eng
ប្រធាន PDP Center

លោក **ទូច ទុម្ព**
Mr. TOUCH Tum
នាយក VIGILANCE

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

កញ្ញា **សយ សារា វឌ្ឍនី**
Ms. SAY Sara Vathany
នាយិកា CWCC

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith
**ឥស្សរជន**

លោក **សឺន សែត**
Mr. SEN Set
**ឥស្សរជន**

ស.ប្រ.ក.៣/លេខ ០៨/០៨ គ.ប.ស.យ/អ.ក

# របាយការណ៍សង្កេតបឋមលើកទី ៥
# ស្តីពី
# បរិយាកាសឃោសនាបោះឆ្នោត ឆ្នាំ ២០០៨ រយៈពេលមួយសប្តាហ៍ដំបូង

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៨*

## ១- ដំណើរការ និងបរិយាកាសទូទៅក្នុងកំឡុងពេលឃោសនាបោះឆ្នោត

គណៈកម្មាធិការ ខុមហ្វ្រែល សង្កេតឃើញថា បរិយាកាសសន្តិសុខជាទូទៅក្នុងដំណើរការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ក្នុងសប្តាហ៍ទី ១ នេះ **មានសភាពប្រសើរជាង**បើប្រៀបធៀបទៅនឹងការបោះឆ្នោតឆ្នាំ២០០៣។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ករណីបំភិតបំភ័យ គំរាមកំហែង រារាំង ពាក់ព័ន្ធនឹងគណបក្សនយោបាយដែលកំពុងកើតមានចំពោះអ្នកនយោបាយ និងសកម្មជនគណបក្សសំខាន់ៗ ជាបន្តបន្ទាប់រួមមានចំនួន **១៦** ករណី[១] ។ ករណីជាក់ស្តែងមួយចំនួនមានដូចខាងក្រោមនេះ

- ករណីបាញ់សម្លាប់អនុប្រធានភូមិមកពីគណបក្សប្រជាជនកម្ពុជានៅក្នុងភូមិជ្រៃសុខុម ឃុំដំរិល ស្រុកអូរាំងឪ ខេត្តកំពង់ចាមនៅថ្ងៃទី ២៧ មិថុនា។
- ករណីគំរាមកំហែងចំពោះបេក្ខជនតំណាងរាស្ត្រគណបក្សសមរង្ស៊ីលោកស្រី មួរ សុខហួរ ចំនួនពីរលើកនៅក្នុងខេត្តកំពត។ លើកទី ១ មានការប៉ុនប៉ងបង្ករបួសស្នាមពីសំណាក់អនុប្រធានភូមិ និងប៉ូលិសប៉ុស្តិ៍ ភូមិស្ទឹងកែវ មកពីគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី ២៨ មិថុនា នៅក្នុងភូមិវត្តអង្គរ ឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត។ លើកទី ២ មានការប្រើអំពើហិង្សាពីសំណាក់ក្រុមទាហានកាលពីថ្ងៃទី ៣០ មិថុនា នៅផ្សារកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច។
- ករណីបាញ់គំរាមទៅលើបេក្ខជនតំណាងរាស្ត្រគណបក្សនរោត្តមរណឬទ្ធិ លោក ស៊ុត ឌីណា នៅត្រង់ចំនុចផ្សារតាគ្រី ឃុំតាគ្រី ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ មិថុនា ២០០៨

ករណីដែលសម្តេចក្រុមព្រះ ព្រះប្រធានគណបក្សនយោបាយ និងជាបេក្ខជនតំណាងរាស្ត្រដ៏មានសក្តានុពល មួយរូបនៅមិនទាន់បានចូលរួមធ្វើសកម្មភាពដោយផ្ទាល់ នៅក្នុងយុទ្ធនាការរកសម្លេងឆ្នោត។

---

[១] ករណីគំរាមកំហែង ៨ ករណី។ ករណីបំផ្លាញទ្រព្យសម្បត្តិ គណបក្សនយោបាយមានចំនួន ៣ ករណី។ ករណីរំលោភនីតិវិធីឃោសនាបោះឆ្នោតមាន ៥ករណី។

ភាពមិនប្រក្រតីផ្សេងៗទៀតមានដូចជា ការបង្ខំឱ្យបកផ្លាកខិតប័ណ្ណគណបក្ស បង្ខំឱ្យទម្លាក់ស្លាកគណបក្ស ការហាម ការចងបដានៅតាមទីសាធារណៈ ការប៉ុនប៉ងគំរាមសម្លាប់ទាំងគ្រួសារ...។ មានករណីគំរាមកំហែងទៅលើសមាជិកគណបក្សសម រង្ស៊ី និងគណបក្សនរោត្តមរណឬទ្ធិ ចំនួន ៨ ករណី។ ចំណែកឯករណីបំផ្លាញទ្រព្យសម្បត្តិគណបក្សនយោបាយ មានចំនួន ៣ ករណីនៅខេត្តបាត់ដំបង។ ករណីរំលោភនីតិវិធីឃោសនាបោះឆ្នោតមាន ៤ ករណី នៅខេត្តកំពង់ចាម កំពង់ឆ្នាំង បន្ទាយមានជ័យ កណ្តាល និងខេត្តកំពត។

ការសង្កេតឃើញថា មានការរំលោភទៅលើច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោត ពីសំណាក់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធតាមស្ថាប័នរដ្ឋជាច្រើន ដោយមិនត្រឹមតែបានចូលរួមក្នុងសកម្មភាពឃោសនា ក្នុងម៉ោងធ្វើការ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើប្រាស់ធនធានរបស់រដ្ឋជាពិសេស រថយន្តដែលត្រូវបានគេសង្កេតឃើញថា បានដោះស្លាក លេខរដ្ឋចេញដោយបំពាក់ស្លាកលេខឯកជន ឬគ្មានស្លាកលេខតែម្តង ហើយដង្ហែរក្នុងក្បួនឃោសនារបស់គណបក្សនយោបាយកាន់អំណាចទាំងពីរ ជាពិសេសគណបក្សប្រជាជនកម្ពុជា ចំនួនប្រហែល ៣៥ ករណី។

សកម្មភាពចែកអំណោយនៅតែបន្តកើតមាននៅឡើយជាក់ស្តែងដូចជាការចែកសារុង នៅក្នុងខេត្តកំពង់ឆ្នាំង និង ការចែកថ្នាំពេទ្យនៅបន្ទាយមានជ័យ ជាដើម។

នៅក្នុងកំឡុងពេលនេះ ខុមហ្វ្រែល បានទទួល និងតាមដានករណីបណ្តឹងសរុបចំនួន ៨ ដែលក្នុងនោះ ៥ ករណី នៅក្នុងខេត្តបាត់ដំបង ដែលមានបណ្តឹងរបស់គណបក្សសម រង្ស៊ីចំនួន ៤ និងគណបក្សប្រជាជនកម្ពុជា ចំនួន១ផងដែរ។ បណ្តឹងរបស់គណបក្សសមរង្ស៊ីច្រើនផ្តោតលើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ របស់គណបក្សពីសំណាក់មន្ត្រីអាជ្ញាធរមូលដ្ឋាន រួមទាំងនគរបាលជាដើម។ ចំណែកឯបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជា គឺប្តឹងគណបក្សសមរង្ស៊ី ពីបទធ្វើសកម្មភាព ឃោសនាខុសច្បាប់នៅក្នុងសាលារៀន។ ខុមហ្វ្រែល ក៏បាននឹងបន្តតាមដានបណ្តឹងចំនួន៣ផ្សេងទៀតដែលក្នុងនោះនៅខេត្ត កំពត ចំនួន ១ ខេត្តកំពង់ឆ្នាំងចំនួន ១ និងខេត្តកំពង់ធំ ចំនួន ១។ នៅខេត្តកំពត គណបក្សសម រង្ស៊ីប្តឹងទៅ លើគណបក្ស ប្រជាជនកម្ពុជាពីបទយករថយន្តពាក់ស្លាកលេខ ខម យកទៅឃោសនា ដោយបិទស្លាកសញ្ញាគណបក្សប្រជាជនកម្ពុជា។ នៅខេត្តកំពង់ធំ មានការប្តឹងពីសមាជិកគណបក្សប្រជាជនកម្ពុជា ទៅគំរាមកំហែងសមាជិកសម រង្ស៊ីមិនឱ្យលើកស្លាក គណបក្សនៅមុខផ្ទះ។ នៅខេត្តកំពង់ឆ្នាំង បណ្តឹងរបស់ គណបក្ស សម រង្ស៊ី ទៅលើគណបក្សប្រជាជនកម្ពុជា ថាបានយក អំណោយទៅចែកដល់ប្រជាពលរដ្ឋនៅឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨។

ករណីបណ្តឹងទាំងនោះភាគច្រើនត្រូវបាន គឃ/សប ចារបដិសេធដែលមានចំនួន ៤ ករណី និងកំពុងដោះស្រាយ ២ ករណីនិងបញ្ជូនមក គខ/កប ចំនួន ២ ករណី ហើយបានសម្រុះសម្រួល ១ ករណី។

**១-៤ ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយ**

ក្នុងដំណាក់កាលឃោសនាបោះឆ្នោតនេះ ប្រព័ន្ធផ្សព្វផ្សាយអេឡិត្រូនិចរដ្ឋទាំងបីបានផ្តល់ពេលវេលា យ៉ាងច្រើនដល់ ការអប់រំអ្នកបោះឆ្នោត និងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការចាក់ផ្សាយកម្មវិធីនានា។ ជាមួយគ្នានេះ កម្មវិធីនានាដែលមាននិន្នាការគាំទ្រគណបក្សកាន់អំណាច និងរិះគន់គណបក្ស មិនកាន់អំណាចក៏ត្រូវបានផ្អាកការផ្សាយ។

ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍ឯកជនយ៉ាងតិច ៣០ ស្ថានីយដែលគាំទ្រគណបក្សប្រជាជនកម្ពុជា បន្តរំលោភបទបញ្ជា នីតិវិធី និងសេចក្តីណែនាំ របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ទាក់ទិនគោលការណ៍ស្មើភាព និងសមធម៌ក្នុងការផ្តល់កម្មវិធី ឬជួលម៉ោងផ្សាយដល់គណបក្សនយោបាយផ្សេងៗ។ ឧទាហរណ៍ វិទ្យុបាយ័ន មិនបានគោរពតាមសេចក្តីណែនាំរបស់ គ.ជ.ប និងផ្តល់ឱកាសដល់គណបក្សផ្សេងក្នុងការផ្សព្វផ្សាយ ប៉ុន្តែវិទ្យុនេះ និងវិទ្យុគាំទ្រគណបក្សប្រជាជនកម្ពុជាដទៃទៀតនៅបន្តផ្សាយកម្មវិធី "នាទីវប្បធម៌ខ្មែរ" ដែលមិនបានប្រកាសលក់ម៉ោងផ្សាយដល់គណបក្សនយោបាយទេនោះ [២] នៅតែបន្តផ្សាយឱ្យគណបក្សប្រជាជនកម្ពុជាតែមួយ និងរិះគន់ដល់គណបក្សផ្សេងៗ។ ចំណែក គណបក្សមិនកាន់អំណាចមានលទ្ធភាពជួលម៉ោងផ្សាយពីវិទ្យុឯកជនមួយចំនួនតូច(ពីរ ឬបីស្ថានីយ) ដែលលក់ម៉ោងផ្សាយដល់គណបក្សនយោបាយដើម្បីឃោសនាពីគណបក្សរបស់ខ្លួន និងវាយប្រហារទៅលើរាជរដ្ឋាភិបាល និងគណ-បក្សប្រជាជនកម្ពុជា។

**២- សិទ្ធិអ្នកបោះឆ្នោត ខ្វះរងការគំរាមកំហែង ដោយបាត់បង់សិទ្ធិ និងខ្វះព័ត៌មានស្តីពីការបោះឆ្នោត**

**២-១ ការលុបឈ្មោះអ្នកបោះឆ្នោតខុសនីតិវិធី**

មានការព្រួយបារម្ភ អំពី**ការបាត់បង់សិទ្ធិអ្នកបោះឆ្នោត** ដែលបណ្តាលមកពីការលុបឈ្មោះមិនត្រឹមត្រូវតាមនីតិវិធី។ តាមរបាយការណ៍ធ្វើសវនកម្មលើបញ្ជីឈ្មោះអ្នកបោះឆ្នោតលើកទី ២ [៣] បានរកឃើញថា ក្នុងចំណោមឈ្មោះអ្នកបោះឆ្នោតប្រមាណជាង ៥៨ ម៉ឺននាក់ដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតនោះ មានឈ្មោះអ្នកបោះឆ្នោតជាង **៥៧ ពាន់នាក់ស្មើនឹងប្រហែល ១០% គឺជាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបោះឆ្នោត** [នៅក្នុងទាំង ២៤ ខេត្ត/ក្រុង]។ ដូច្នេះអ្នកទាំងនោះ នឹងបាត់បង់សិទ្ធិបោះឆ្នោតជាស្វ័យប្រវត្តិ។ អ្នកដែលទទួលខុសត្រូវលើការលុបឈ្មោះខុសនេះ គួរតែត្រូវទទួលទោសពីបទដកហូតសិទ្ធិអ្នកបោះឆ្នោត។

**២-២ ការចែកប័ណ្ណព័ត៌មានមិនបានដល់ដៃអ្នកបោះឆ្នោត**

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីលទ្ធផលចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានអ្នកបោះឆ្នោតប្រមាណ ៨៥%ប៉ុណ្ណោះនៃអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតប្រមាណជាង ៨លាននាក់ បានទទួលប័ណ្ណព័ត៌មាន ដូច្នេះនៅមានអ្នកបោះឆ្នោតជិត ១លាន ២សែន នាក់ទៀតមិនបានទទួលប័ណ្ណព័ត៌មាននេះ។ អ្នកសង្កេតការណ៍ ខុមហ្វ្រែល បានវាយតម្លៃថា អ្នកមិនទាន់ទទួលប័ណ្ណព័ត៌មាននេះ អាចមានច្រើនរាប់ម៉ឺននាក់នៅទីប្រជុំជននៃខេត្ត ក្រុងនិមួយៗ ជាពិសេសក្រុងភ្នំពេញ ដោយសារការរើសអើងខាងនយោបាយ។ មានការព្រួយបារម្ភថា អ្នកដែលពុំបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនឹងអាចយល់ច្រឡំ ឬត្រូវគេពន្យល់ថា ពុំមានសិទ្ធិបោះឆ្នោតទេ ឬក៏អាចពន្យល់ខុសថា អ្នកនោះពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

---

[២] សេចក្តីជូនដំណឹងរបស់ គជប ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៨ ឱ្យដឹងថា: មានវិទ្យុតែ ៣ ប៉ុណ្ណោះប្រកាសលក់ម៉ោង ផ្សាយដល់គណបក្សនយោបាយ រួមមាន វិទ្យុ FM 93.5 MHz វិទ្យុ FM 104 MHz និងវិទ្យុ FM 105 MHz

[៣] ធ្វើឡើងដោយ ខុមហ្វ្រែល និងនិកហ្វិច ដោយមានជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអិន ឌី អាយ។

**៣- ភាពមិនស្របច្បាប់នៃនីតិវិធី និងកំណត់ហេតុបូកសរុបលទ្ធផលនៅថ្នាក់ឃុំ សង្កាត់**

យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមាត្រា ១០៩ និង ១១០ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) **ពុំមាននីតិវិធីក្នុងការបូកសរុបលទ្ធផលបោះឆ្នោតក្នុងឃុំ សង្កាត់នោះទេ** ប៉ុន្តែ គឃ/សប មានតួនាទីត្រឹមតែបញ្ជូនកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់ការិយាល័យបោះឆ្នោតទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប)ប៉ុណ្ណោះ ប៉ុន្តែ គ.ជ.ប បានចែងនៅក្នុងបទបញ្ជា និងនីតិវិធីប្រការ ៨.១៩ ស្តីពីកិច្ចប្រតិបត្តិការរបស់ គឃ/សប ក្នុងការធ្វើកំណត់ហេតុ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមិនមែន**នីត្យានុកូល**។ គខ/កប នឹងធ្វើកំណត់ហេតុបូក សរុបចេញពីកំណត់ហេតុបូកសរុលទ្ធផលបោះឆ្នោតរបស់ គឃ/សប ដែល**អនីត្យានុកូល**។ (សូមមើលការសិក្សាវិភាគលម្អិតលើករណីនេះដោយឡែកភ្ជាប់មកជាមួយ)។

**៤- ផែនការរបស់ខុមហ្វ្រែល ក្នុងការដាក់ពង្រាយ និងសកម្មភាពសង្កេតការណ៍**

សម្រាប់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ នេះ ខុមហ្វ្រែល នឹងពង្រាយអ្នកសង្កេតការណ៍ប្រមាណប្រហែល ១ ម៉ឺននាក់ ជាពិសេសនៅក្នុង ១៥ ខេត្ត ក្រុងធំៗ។ ក្នុងចំណោមអ្នកសង្កេតការណ៍ទាំងនោះ មានអ្នកសង្កេតការណ៍ប្រមាណ៨.៧០០នាក់ ត្រូវបានតម្រូវឱ្យសង្កេតក្រៅការិយាល័យក្នុងទីតាំងការិយាល័យបោះឆ្នោតមួយ(ក្នុងបរិវេណសាលារៀន ឬវត្ត អ្នកសង្កេតការណ៍ម្នាក់ ក្នុងទីតាំងការិយាល័យបោះឆ្នោតមួយ) ដើម្បីសង្កេតមើលពីភាពមិនប្រក្រតីនានា[៤] ហើយនិងជួយអ្នកបោះឆ្នោតដែលជួបបញ្ហា ដូចជារកឈ្មោះមិនឃើញ ឬត្រូវបានគេបដិសេធសិទ្ធិបោះឆ្នោតជាដើម រហូតដល់ម៉ោង ១១ ថ្ងៃត្រង់។ ហើយបន្ទាប់មកអ្នកសង្កេតការណ៍ នឹងត្រូវស្នើឱ្យចូលសង្កេតក្នុងការិយាល័យ រហូតដល់រាប់សន្លឹកឆ្នោតហើយ។

ដើម្បីចូលរួមក្នុងផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត ខុមហ្វ្រែល ពង្រឹង និងធ្វើការហ្វឹកហ្វឺនពិសេស ដល់អ្នកសង្កេតការណ៍ចំនួន១.៣១៩ នាក់ នៅក្នុង១.៣១៩ ការិយាល័យបោះឆ្នោតដែលបានជ្រើសរើសដោយចៃដន្យនៅទូទាំងប្រទេស។ អ្នក-សង្កេតការណ៍ទាំងនេះ នឹងបញ្ជូនព័ត៌មានស្តីពីភាពមិនប្រក្រតីធ្ងន់ធ្ងរ និងលទ្ធផលឆ្នោតយ៉ាងលឿនមកស្នាក់ការកណ្តាល។

ខុមហ្វ្រែល ក៏បាន និងកំពុងចាត់ចែង និងសម្របសម្រួលអ្នកសង្កេតការណ៍ជាតិ និងបរទេស មកពីអង្គការមិនមែនរដ្ឋាភិបាលប្រមាណ ១.៣០០ នាក់ទៀតឱ្យចូលរួមសង្កេតការណ៍បោះឆ្នោតផងដែរ។

---

[៤] ពីម៉ោង ៦:៣០ នាទី ដល់ម៉ោង ៧:៣០ នាទីព្រឹក អ្នកសង្កេតការណ៍ឋិតនៅក្នុងការិយាល័យបោះឆ្នោតមួយដើម្បីសង្កេតមើលដំណើរការបើកការិយាល័យបោះឆ្នោត។ ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១ ព្រឹក អ្នកសង្កេតការណ៍ស្ថិតនៅខាងក្រៅការិយាល័យបោះឆ្នោត ដើម្បីសង្កេត និងជួយអ្នកបោះឆ្នោត នៅក្នុងទីតាំងការិយាល័យ។ ពីម៉ោង ១១ ព្រឹក ដល់ម៉ោង ៣ រសៀល អ្នកសង្កេត-ការណ៍សង្កេតនៅក្នុង និងក្រៅការិយាល័យបោះឆ្នោត (ចល័តសង្កេតក្នុងចំនួន ៤-៥ ការិយាល័យ) ដែលមាននៅក្នុងទីតាំងការិយាល័យបោះឆ្នោត។ ការចេញ និងចូលក្នុងការិយាល័យមួយអាចប្រើរយៈពេល៣០នាទី ដើម្បីសង្កេត។ ចាប់ពីម៉ោង ៣ រសៀល រហូតដល់រាប់ហើយ អ្នកសង្កេតការណ៍ជ្រើសរើស ហើយចូលទៅសង្កេតខាងក្នុងការិយាល័យតែមួយ ហើយចាប់ផ្តើមសង្កេតដំណើរការបញ្ចប់ការបោះឆ្នោត រៀបចំកំណត់ហេតុ និងដំណើរការរាប់ កត់ត្រាតួលេខ និងព័ត៌មានពាក់ព័ន្ធនានា។

ខុមហ្វ្រែល ក៏មានរួមបញ្ចូលអ្នកសង្កេតការណ៍ពិសេស ចំនួនប្រហែល ២៥០ នាក់ ឃ្លាំមើលការចូលរួម របស់យុវជន និងស្ត្រីក្នុងវិស័យនយោបាយផងដែរ ដូចជាចំនួន និងទស្សនៈចូលរួមក្នុងការបោះឆ្នោត ។

ទន្ទឹមនឹងនេះ ខុមហ្វ្រែល ក៏មានអ្នកអង្កេតមើលប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ និងទូរទស្សន៍ សារព័ត៌មាន) ចំនួន ១២ នាក់ដែរ ។

អនុសាសន៍

- *អ្នកនយោបាយ អ្នកគាំទ្រគណបក្សនិមួយៗ និងអាជ្ញាធរមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សុំកុំប្រើអំពើហិង្សា ក្នុងការដោះស្រាយបញ្ហា និងត្រូវចេះអត់ឱនឱ្យគ្នា រស់នៅក្នុងសហគមន៍ជាមួយគ្នា បើទោះបីមានមតិ និងសកម្មភាពនយោបាយខុសគ្នាក៏ដោយ*
- *សូមឱ្យ គ.ជ.ប បន្តចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដល់អ្នកបោះឆ្នោតឱ្យបានគ្រប់ចំនួនអ្នកដែលមានឈ្មោះបោះឆ្នោត*
- *អាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងដំណើរការបោះឆ្នោតពីគ្រប់គណបក្សនយោបាយ ។*
- *អ្នកពាក់ព័ន្ធការបោះឆ្នោតត្រូវគោរព និងអនុវត្តតាមច្បាប់ បទបញ្ជា នីតិវិធី និងសេចក្តីណែនាំបោះឆ្នោតដើម្បីជម្រុញឱ្យការឃោសនាបោះឆ្នោតនិងដំណើរការបោះឆ្នោត រាប់សន្លឹកឆ្នោតប្រព្រឹត្តទៅមានតម្លាភាព សេរី និងយុត្តិធម៌ ។*

*សម្រាប់ព័ត៌មានផ្សេងៗសូមទាក់ទង:*


- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១
- លោក **ច័ន្ទ ដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១


*បេសកកម្មទី ១ របស់ ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយ ដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ។*